ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
អគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ
នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ

# របាយការណ៍

## ស្តីពី

## សកម្មភាពការងារនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ឆ្នាំ២០០៩ និងទិសដៅអនុវត្តន៍ឆ្នាំ២០១០

រៀបចំឡើងដោយលោក **អ៊ុច គីមយ៉ុន**
ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ក្រសួងពាណិជ្ជកម្ម
ភ្នំពេញ ២០១០

# របាយការណ៍សន្និបាតបូកសរុបការងារ ប្រចាំឆ្នាំ២០០៩ និងទិសដៅឆ្នាំ២០១០

**ក្រសួងពាណិជ្ជកម្ម ថ្ងៃទី២៤-២៦ ខែមីនា ឆ្នាំ២០១០**

លោក **អ៊ុច គឹមយ៉ុន**

ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ (D/ICO)

1

# កម្មវត្ថុ

- វឌ្ឍនភាពការងារបំពេញដោយនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ (D/ICO) នៅឆ្នាំ២០០៩
- វឌ្ឍនភាពការងារនៅក្រោមការអនុវត្តអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម (TRADE SWAp)
- ផែនការ និងទិសដៅ សម្រាប់ឆ្នាំ២០១០

2

# មាតិកា

១. វឌ្ឍនភាពការងារផ្នែកស្ថាប័ន

២. វឌ្ឍនភាពការងារផ្នែកប្រតិបត្តិការ

៣. ផែនការការងារឆ្នាំ២០១០ និងទិសដៅ

3

ផ្នែក I

# វឌ្ឍនភាពការងារផ្នែកស្ថាប័ន

4

## ការកសាងសមត្ថភាព D/ICO

- ដោយមានការគាំទ្រពីទីប្រឹក្សានានា រចនាសម្ព័ន្ធថ្មីមួយត្រូវបានរៀបចំឡើង ដោយតម្រូវតាមអាណត្តិការងារ និងការផ្តោតរបស់នាយកដ្ឋាន
- រចនាសម្ព័ន្ធថ្មីនេះ ជួយជម្រុញឱ្យមានការរៀបចំផែនការកសាងសមត្ថភាពថ្មីមួយសម្រាប់ D/ICO ស្របតាមការងាររបស់សរសរស្តម្ភទី ៣ និងដោយសហការជាមួយនាយកដ្ឋានបុគ្គលិក
- ផែនការងារឆ្នាំ២០១០ មានរៀបចំឡើងក្នុងជំនួបប្រជុំក្រៅផ្លូវការប្រចាំឆ្នាំរបស់ D/ICO (ខែឧសភា ឆ្នាំ២០០៩)

5

ផ្នែក II

# វឌ្ឍនភាពការងារផ្នែកប្រតិបត្តិការ

6

## វឌ្ឍនភាពការងារអភិក្រម ឆ្នាំ២០០៩

- មូលនិធិពហុម្ចាស់ជំនួយត្រូវបានបង្កើតឡើង
- សេចក្តីសម្រេចស្តីពីអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្មត្រូវបានអនុម័តរួចដែល មានចុះហត្ថលេខាដោយសម្តេចនាយករដ្ឋមន្ត្រី (សមាជិកគណៈកម្មាធិការអនុវត្តន៍)
- បានដាក់ឱ្យអនុវត្តន៍ក្របខ័ណ្ឌតាមដានត្រួតពិនិត្យ និងវាយតម្លៃ
- ផែនការទិសដៅ (roadmap) បានបញ្ចប់សម្រាប់សរសរស្តម្ភទី ១ និង ផែនការទិសដៅសម្រាប់សរសរស្តម្ភទី ៣ កំពុងត្រូវរៀបចំឡើង
- បង្ហោះវេបសាយ Trade SWAp
- មានយុទ្ធសាស្ត្រប្រាស្រ័យទាក់ទងថ្មី

7

## វឌ្ឍនភាពការងារអភិក្រម ឆ្នាំ២០០៩

**គណៈកម្មាធិការអនុវត្តន៍ :**

ឯកឧត្តម **ចាន់ សូរស័ក្តិ** ជាប្រធាន

មានសមាជិក ២០រូប មកពីអន្តរក្រសួង

ពិនិត្យឡើងវិញ និងធ្វើការសម្រេចលើការងាររបស់អភិក្រម និង

ការអនុវត្តគម្រោងដែលពាក់ព័ន្ធ

បានជួបប្រជុំចំនួន ២ដង

8

**ការសម្ពោធដាក់ឱ្យអនុវត្តកម្មវិធីគាំទ្រការអភិវឌ្ឍពាណិជ្ជកម្ម (TDSP)**




9

## វឌ្ឍនភាពការងារ TDSP ឆ្នាំ២០០៩ (ស្ថាប័ន)

- ចាត់តាំងមន្ត្រី D/ICO ទៅតាមមុខងារទាក់ទងនឹង TDSP
- រើសទីប្រឹក្សាជាតិ និងអន្តរជាតិឱ្យចូលបម្រើការងារក្នុងផ្នែកសំខាន់ៗ របស់កម្មវិធី
- បង្កើតគណៈកម្មាធិការពិនិត្យការងារលទ្ធកម្ម និងគណៈកម្មាធិការអនុវត្តន៍
- បង្កើតយន្តការដាក់ពាក្យបណ្តឹង យន្តការពិនិត្យការងារឡើងវិញ សវនកម្ម ក្របខ័ណ្ឌអភិបាលកិច្ចល្អ
- បង្កើតសៀវភៅណែនាំលើប្រតិបត្តិការ សៀវភៅណែនាំលើការងារលទ្ធកម្ម សៀវភៅណែនាំបន្ថែមលើហិរញ្ញវត្ថុ សម្រាប់ការអនុវត្ត TDSP

10

## វឌ្ឍនភាពការងារ TDSP ឆ្នាំ២០០៩ (ការកសាងសមត្ថភាព)

- មានការសម្របសម្រួលការងារសសរស្តម្ភរបស់Trade SWAp ជំនួបប្រជុំតាមសសរស្តម្ភ លើកកម្ពស់ការយល់ដឹងអំពីទិសដៅ របៀបធ្វើការងារ និងលទ្ធផលរំពឹងទុករបស់ SWAp និង TDSP ដល់តំណាងរាជរដ្ឋាភិបាល និងវិស័យឯកជន
- លើកកម្ពស់ការយល់ដឹងអំពី TDSP ដល់សមាជិកគណៈកម្មាធិការអនុវត្តន៏ និងទីភ្នាក់ងារអនុវត្តន៏
- គ្រប់គ្រងលើការងារផ្តោតលើការអនុវត្តតាមគម្រោង ទៅការអនុវត្តតាមកម្មវិធី
- មានសកម្មភាពបណ្តុះបណ្តាលបឋម សម្រាប់មន្ត្រី D/ICO លើការគ្រប់គ្រងគម្រោង ការងារលទ្ធកម្ម
- មានកម្មវិធីបង្ហាត់បង្ហាញការងារដល់មន្ត្រី DICO
- មានរៀបចំកំណត់ភារកិច្ចសម្រាប់មន្ត្រីនីមួយៗ សំណើសុំអនុវត្តប្រាក់លាភការបន្ថែម នៅក្នុងក្រសួងពាណិជ្ជកម្ម ប៉ុន្តែគម្រោងនេះត្រូវបានបញ្ចប់ដោយរាជរដ្ឋាភិបាល នៅខែធ្នូ ឆ្នាំ២០០៩

11

## វឌ្ឍនភាពការងារ TDSP ឆ្នាំ២០០៩ (ការអនុវត្ត)

- ផែនការទិសដៅ(roadmap) សម្រាប់សសរស្តម្ភទី ១ មានរួចរាល់ហើយ រីឯផែនការទិសដៅសម្រាប់សសរស្តម្ភទី ៣ កំពុងរៀបចំឡើង ។
- មានរៀបចំជំនួបប្រជុំមួយចំនួនជាមួយទីភ្នាក់ងារអនុវត្តន៏ ដើម្បីផ្សព្វផ្សាយ អំពី TDSP និងនីតិវិធីលម្អិត ដើម្បីទទួលបានមូលនិធិគាំទ្រពី TDSP
- ចន្លោះខែតុលា ឆ្នាំ២០០៩ ដល់ខែមករា ឆ្នាំ២០១០ មានទទួលបានសំណើ-គម្រោងចំនួន ៤៨ ពីទីភ្នាក់ងារអនុវត្តន៏ចំនួន ១៤ ផ្សេងៗ គ្នា ដែលត្រូវបាន ចុះបញ្ជី ពិនិត្យឡើងវិញ និងបែងចែកជា ៤ចំណាត់ថ្នាក់ (រួមទាំង សំណើគម្រោង ១៥របស់ក្រសួងពាណិជ្ជកម្ម)

12

## វឌ្ឍនភាពការងារ TDSP ឆ្នាំ២០០៩ (ការអនុវត្ត) ~ ត

- គណៈកម្មាធិការអនុវត្តន៏បានពិនិត្យអនុម័តសំណើគម្រោង ១១ នៅខែកុម្ភៈ ឆ្នាំ២០១០ ។ សំណើគម្រោង ៧ ជារបស់ក្រសួងពាណិជ្ជកម្ម សំណើគម្រោង ២ ជារបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករ សំណើគម្រោង ១ ជារបស់សាលាភូមិន្ទ រដ្ឋបាល និង ១ ជារបស់ CAMFEBA ដែលមានសំណើ ទឹកប្រាក់សរុបចំនួន ១,៥លានដុល្លារអាមេរិក ។ គណៈកម្មាធិការអនុវត្តន៏នឹងបើកអង្គប្រជុំម្តងទៀត នៅពេលសំណើគម្រោង ១០ ទៀតមានរៀបចំរួចរាល់ ។
- ទីភ្នាក់ងារអនុវត្តន៏ទាំងអស់ទទួលបានមតិយោបល់ និងការជួយកែសម្រួលផ្នែក បច្ចេកទេស និងហិរញ្ញវត្ថុ ក្នុងសំណើគម្រោងរបស់ពួកគេ ។
- សំណើគម្រោងមួយចំនួនរបស់ក្រសួងពាណិជ្ជកម្មនឹងត្រូវដាក់សុំការអនុម័តជាបន្ត ទៀត ដូចជា ផែនការកសាងសមត្ថភាព ផែនការមេរបស់ ICT ការគាំទ្រដល់ យន្តការតំបន់ត្រីកោណកម្ពុជា-វៀតណាម-ឡាវ ។

13

## ក្របខ័ណ្ឌសមាហរណកម្ម [EIF] (គម្រោងដំណាក់កាលទី១)

- ដោយមានការគាំទ្រពី UNDP/TRADE D/ICO បានរៀបចំសំណើគម្រោង EIF ដំណាក់កាលទី ១ និងទទួលបានការឯកភាពផ្តល់មូលនិធិ ប្រកបដោយជោគជ័យ
- គម្រោងមានរយៈពេល ៥ឆ្នាំ ដោយមានមូលនិធិ ១,៥លានដុល្លារ និងត្រូវគ្រប់គ្រងដោយ D/ICO
- គម្រោងរំពឹងថានឹងចាប់ផ្តើមនៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០១០

14

…បានដាក់សំណើគម្រោងដំណាក់កាលទី ១ ក្នុងកំឡុងពេល សិក្ខាសាលាស្តីពីជំនួយពាណិជ្ជកម្មសកលលោកលើកទី ២



15

## ក្របខ័ណ្ឌសមាហរណកម្ម [EIF] (គម្រោងដំណាក់កាលទី១)

- នៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០០៩ រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងពាណិជ្ជកម្ម ទទួលបានមូលនិធិ EIF ដំណាក់កាលទី ១ ( ប្រទេសទី ៣ ក្នុងចំណោមប្រទេស ៤៥)




16

## ចែករំលែកបទពិសោធន៍ជាមួយប្រទេសដទៃទៀត

- នៅឆ្នាំ២០០៩ D/ICO បានទទួលប្រតិភូពីប្រទេសឡាវ (TDSP) និងប្រទេសប៊ុយតាន ដើម្បីចែករំលែកបទពិសោធន៍អំពីការងារបញ្ជ្រាបពាណិជ្ជកម្ម
- នៅឆ្នាំ២០១០ ប្រតិភូពីប្រទេសយេម៉ែន និងប្រទេសប៉ាពីញូវហ្គីណេ បានដាក់សំណើសុំធ្វើទស្សនកិច្ចមកកម្ពុជា ដែលការងារនេះត្រូវសម្របសម្រួលដោយ D/ICO ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍

17

## កិច្ចប្រជុំតុមូលរបស់ WTO (កញ្ញា ២០០៩)




18

ផ្នែក III

# ផែនការការងារឆ្នាំ២០១០ និងទិសដៅ

19

## គាំទ្រដល់ការងារទំនាក់ទំនងអន្តរជាតិរបស់ក្រសួងពាណិជ្ជកម្ម

- D/ICO នឹងបន្តធ្វើការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍ទាំងអស់របស់ក្រសួងពាណិជ្ជកម្ម ដើម្បីគាំងគងធនធានសម្រាប់ការងារក្រោមរបៀបវារៈអភិវឌ្ឍន៍ពាណិជ្ជកម្មកម្ពុជា
- ពង្រឹងការតស៊ូមតិ និងការផ្សព្វផ្សាយអំពីជំនួយបច្ចេកទេសទាក់ទងនឹងពាណិជ្ជកម្មដល់នាយកដ្ឋាន-មន្ទីរនានារបស់ក្រសួងពាណិជ្ជកម្ម និងអន្តរក្រសួងនៅក្នុងជួររាជរដ្ឋាភិបាលកម្ពុជា

20

## ទស្សនកិច្ចរបស់ប្រតិភូពីប្រទេសប៊ូតាន




21

## អភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម (TRADE SWAP)

- រៀបចំជំនួបប្រជុំក្រៅផ្លូវការរបស់អភិក្រមគ្របដណ្តប់លើវិស័យ ពាណិជ្ជកម្ម [Trade SWAp retreat] (ខែមេសា ឆ្នាំ២០១០)
- ពិនិត្យបញ្ចប់ផែនការទិសដៅ (road maps) របស់សរសរស្តម្ភទាំងអស់
- ធ្វើបច្ចុប្បន្នភាពលើផែនការ ៣ឆ្នាំ
- អនុវត្តយុទ្ធសាស្ត្រទំនាក់ទំនង (communication strategy)
- ពិនិត្យបញ្ចប់ការងាររៀបចំក្របខ័ណ្ឌតាមដានត្រួតពិនិត្យ និង វាយតម្លៃអភិក្រម
- ជម្រុញឱ្យមានដៃគូអភិវឌ្ឍន៍កាន់តែច្រើនឡើង ចូលធ្វើការលើផ្នែក ដែលមិនសូវទទួលបានការយកចិត្តទុកដាក់នៅក្រោមអភិក្រម

22

## កម្មវិធីគាំទ្រការអភិវឌ្ឍន៍ពាណិជ្ជកម្ម (TDSP)

- គាំទ្រការអនុវត្តសំណើគម្រោងទាំង១១ ដែលអនុម័តដោយគណៈកម្មាធិការអនុវត្តន៏
- ផ្តល់ការគាំទ្រដល់ទីភ្នាក់ងារអនុវត្តន៏ ដែលបានដាក់សំណើគម្រោង តាមកម្រិត ២ ឬកម្រិត ៣ ដែលបានរៀបចំរួច
- ដាក់សំណើ និងអនុវត្តគម្រោង សម្រាប់ផែនការមេរបស់ ICT ការងារតំបន់ត្រីកោណកម្ពុជា-វៀតណាម-ឡាវ និងផ្គត់ផ្គង់សម្ភារៈសាលប្រជុំ
- ប្រើក្របខណ្ឌតាមដានត្រួតពិនិត្យ និងវាយតម្លៃ ហើយធ្វើបច្ចុប្បន្នភាពលើតារាងម៉ាទ្រិករបស់កម្មវិធី
- អនុវត្តផែនការកសាងសមត្ថភាពសម្រាប់ D/ICO

23

## ក្របខ័ណ្ឌសមាហរណកម្ម (EIF)

- ចាប់អនុវត្តកម្មវិធីនៅខែមេសា ឆ្នាំ២០១០
- ពង្រីកក្រុមការងារ EIF ( ក្រសួងពាណិជ្ជកម្ម + ការិយាល័យទំនាក់ទំនងតាមអន្តរក្រសួង)
- គាំទ្រការរៀបចំសំណើគម្រោងដំណាក់កាលទី ២ដែលធ្វើឡើង ដោយអន្តរក្រសួង
- លើកកម្ពស់ការយល់ដឹង ក្នុងចំណោមវិស័យឯកជន និងអន្តរក្រសួង
- ចែករំលែកបទពិសោធន៏ជាមួយប្រទេសអភិវឌ្ឍន៏តិចតួច និងដៃគូផ្សេងទៀតសម្រាប់សកម្មភាពថ្នាក់តំបន់ ( ឡាវ ប៊ុយតាន នេប៉ាល់)

24

# សេចក្តីសន្និដ្ឋាន

- D/ICO មានតួនាទី និងអាណត្តិការងារ ជម្រុញឱ្យមានការអនុវត្ត អភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្មបានប្រកបដោយជោគជ័យ
- នាយកដ្ឋាននានានៅក្នុងក្រសួងពាណិជ្ជកម្ម និងមន្ទីរពាណិជ្ជកម្ម អាចស្វែងរកការគាំទ្រពីដៃគូអភិវឌ្ឍន៍បាន តាមរយៈ D/ICO
- នៅឆ្នាំ២០១០ នេះ អភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្មនឹងចាប់ ជម្រុញការងារទៅមុខ ហើយការគាំទ្រពីថ្នាក់ដឹកនាំរបស់ក្រសួង ពាណិជ្ជកម្ម គឺជាកត្តាគន្លឹះ ដើម្បីសម្រេចបានជោគជ័យ ។

25